# អ្វីទៅជា ការព្រមព្រៀង "ដោយសេរី , ជាមុន និងផ្តល់ព័ត៌មាន" ?

## ( ការអនុវត្តសិទ្ធិសំរាប់សហគមន៍ជនជាតិដើមភាគតិចក្នុងការគ្រប់គ្រងដីធ្លី)



# អារម្ភកថា

នៅប្រទេសកម្ពុជា ប្រជាពលរដ្ឋដែលរស់នៅតំបន់ជនបទ ជាពិសេសសហគមន៍ជនជាតិដើមភាគតិចភាគច្រើនរស់នៅដោយពឹងផ្អែកទាំងស្រុងលើផលិតផលកសិកម្ម និងអនុផលព្រៃឈើ ។ ការបាត់បង់ដីធ្លី និងធនធានធម្មជាតិ គឺជាបុព្វហេតុចំបងមួយ ដែលធ្វើអោយពួកគាត់រស់នៅក្នុងភាពក្រីក្រកាន់តែខ្លាំង។

ការព្រមព្រៀង ដោយសេរី ជាមុន និងផ្តល់ព័ត៌មាន គឺជាយន្តការមូលដ្ឋានមួយសំរាប់ជួយដល់ សហគមន៍ ជាពិសេសសហគមន៍ជនជាតិដើមភាគតិច ដើម្បីធ្វើការសំរេចចិត្តជាសមូហភាពទៅលើ គំរោង ឬ សកម្មភាពទាំងឡាយណាដែលមានឥទ្ធិពល ឬ ផលប៉ះពាល់ដល់ការរស់នៅ និងសិទ្ធិរបស់ពួកគេក្នុងការកាន់កាប់ដីធ្លី និងធនធាននានាដែលពួកគេបាន និងកំពុងពឹងអាស្រ័យផល។ ពួកគេមាន សិទ្ធិយ៉ាងពេញលេញក្នុងការយល់ព្រម បដិសេដ ឬ ស្នើសុំអោយមានការជូនដំណឹងជាមុនផងដែរ អំពីគំរោងអភិវឌ្ឍន៍នានានៅលើដី ធនធាន ឬ បូរណភាពដែនដីរបស់ពួកគេ។

ដើម្បីជាការចូលរួមចំណែកលើកកំពស់ការយល់ដឹងរបស់សហគមន៍ ជាពិសេសសហគមន៍ ជនជាតិដើមភាគតិច ដែលផ្តោតសំខាន់ទៅលើសិទ្ធិ និងសារៈសំខាន់ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តលើគំរោងអភិវឌ្ឍន៍ណាមួយ អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព ( ឌីភីអេ) បានរៀបចំ ចងក្រងបោះពុម្ពផ្សាយនូវសៀវភៅរូបភាព ដែលមានចំណងជើងថា អ្វីទៅការព្រមព្រៀង “ដោយសេរី ជាមុន និងផ្តល់ព័ត៌មាន”។ ទោះបី សៀវភៅរូបភាពនេះមិនមែនជាច្បាប់ ប៉ុន្តែវាអាចជាជំនួយស្មារតី សំរាប់សហគមន៍ជនជាតិដើមភាគតិច ដើម្បីស្វែងយល់អំពីសិទ្ធិទាំងឡាយ ដែលពួកគេមានសំរាប់ ការពារដីធ្លី វប្បធម៌ និងធនធាននានារបស់ពួកគេ។ យើងខ្ញុំសូមអធ្យាស្រ័យ ចំពោះកំហុសឆ្គងនានាដែលកើតមានឡើងដោយអចេតនា ហើយនិងរីករាយទទួលនូវការផ្តល់មតិកែលំអផងដែរ។


ខណៈពេលដែលគ្រួសាររបស់ពូកាណុងកំពុងដើរទៅមើលចំការរបស់គាត់ រំពេចនោះ ពួកគាត់ ក៏បានជួបជាមួយនឹងលោកពូមេភូមិដែលកំពុងតែជិះកង់នៅតាមផ្លូវ ។
អើកាណុង កំពុងនាំគ្នាទៅណាហ្នឹង?
អីយ៉ា គឺលោកមេភូមិទេតើ! ពួកខ្ញុំកំពុងទៅចំការហ្នឹងណា ព្រោះតាំងពីបុកដាំហើយមិនទាន់ បានទៅមើលផងទេៗ ចុះលោកមេភូមិអញ្ជើញទៅណាដែរ?
អូ! គឺខ្ញុំទៅចូលរួមប្រជុំជាមួយនឹងអ្នកភូមិយើងនៅឯចុងភូមិណា! ចុះកាណុងឯងអត់ទៅចូល រួម ប្រជុំជាមួយនឹងគេទេអី?


មេភូមិ ៖ ថ្ងៃនេះណា គឺលោកគ្រូវុធ និងអ្នកគ្រូដារី ដែលជាអ្នកសំរបសំរួលការអភិវឌ្ឍភូមិយើងនឹងមក បង្ហាញពួកយើងអំពីសិទ្ធិ និងសារៈសំខាន់នៃការចូលរួមរបស់ពួកយើងក្នុងការចូលរួមផ្តល់ប្រឹក្សាយោបល់ និងធ្វើសេចក្តីសំរេចចិត្តថា “ព្រម ឬ មិនព្រម” ទៅលើគំរោងអភិវឌ្ឍជាក់លាក់ណាមួយដែលគ្រោងនឹងប្រតិបត្តិនៅលើដី ដែនដី និងធនធានរបស់ពួកយើង។ ការប្រជុំនេះ គឺវាមានសារៈសំខាន់ណាស់សំរាប់យើងទាំងអស់គ្នា។
គេហៅខ្ញុំអោយទៅចូលរួមដែរ ប៉ុន្តែមិនដឹងថាប្រជុំទាក់ទងពីអ្វីទេ។ ចុះលោកមេភូមិ មានដឹងថាគេប្រជុំពីអ្វីដែរទេ?
ខ្ញុំគិតថាយើងគួរតែទៅចូលរួមប្រជុំជាមួយនឹងគេដែរទៅ ហើយចាំពេលរសៀលចាំយើងទៅចំការវិញ។ ម៉េចដែរ?
អញ្ចឹងក៏បាន!
ល្អណាស់! តោះយើងប្រញាប់ឡើង ជិតដល់ម៉ោងប្រជុំហើយ។


វុធ ៖ ជម្រាបសួរ ពូ មីង និងបងប្អូនទាំងអស់ដែលបានមកចូលរួមប្រជុំនៅថ្ងៃនេះ។ សុខសប្បាយជាទេ! ខ្ញុំបាទឈ្មោះវុធ ចំណែកខាងស្តាំដៃខ្ញុំនេះ គឺដារី ហើយខ្ញុំទាំងពីរនាក់មកសុំជួបប្រជុំថ្ងៃនេះ គឺចង់ជំរាបជូនពីគោលការណ៍សំខាន់មួយ។
មីងកាទុ ៖ តើជាគោលការណ៍អ្វីទៅ ហើយវាមានសារៈសំខាន់យ៉ាងម៉េចបានជាក្មួយរៀបចំការ ប្រជុំបន្ទាន់បែបនេះ?
ដារី ៖ ចាសមីង! គោលបំណងសំខាន់ដែលពួកខ្ញុំអញ្ជើញពូមីង និងបងប្អូនទាំងអស់មកចូលរួម ប្រជុំនៅព្រឹកនេះ គឺដើម្បីផ្សព្វផ្សាយ និងពន្យល់ពីគោលការណ៍មួយហៅថា "ការព្រមព្រៀងៈ ដោយសេរី ជាមុន និងផ្តល់ព័ត៌មាន"។ វាជាផ្នែកមួយនៃវិធីសាស្រ្តសិទ្ធិមនុស្សជាមូលដ្ឋាន ហើយបានចែងនៅក្នុងសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពី សិទ្ធិជនជាតិដើមភាគតិច។


កាំឡើន ៖
តើគោលការណ៍នេះមានអត្ថន័យ
ដូចម្តេចទៅ?
វុធ ៖ ខ្ញុំសុំពន្យល់លើពាក្យសំខាន់ៗទាំងនេះគឺថា ៖
•ការព្រមព្រៀង ៖សំដៅលើការសំរេចចិត្តតាមទំនៀមទំលាប់របស់ជនជាតិដើមភាគតិច
ឬក៏សហគមន៍មូលដ្ឋានផ្សេងទៀតថា យល់ព្រម ឬ មិនយល់ព្រម លើសកម្មភាព ឬ
គំរោងអភិវឌ្ឍន៍ណាមួយដែលគ្រោងធ្វើលើដី ដែនដី និងធនធានធម្មជាតិនានា
ដែលពួកគាត់ កំពុងរស់នៅ និងអាស្រ័យផល។
•ដោយសេរី ៖ គ្មានការបង្ខិតបង្ខំ ការដាក់សំពាធ ឬ គំរាមកំហែងពីអ្នក
ខាងក្រៅដូចជាស្ថាប័នរដ្ឋាភិបាលក្រុមហ៊ុន ឬ បុគ្គលមានអំណាចណាមួយ។
•ជាមុន ៖ អ្នកត្រូវបានគេផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីទទួលបានព័ត៌មាន
វិភាគរាល់ព័ត៌មានទិន្នន័យរបស់សកម្មភាពដែលគ្រោងធ្វើនិងសំរេចចិត្ត។
•ផ្តល់ព័ត៌មាន ៖ អ្នកត្រូវបានផ្តល់ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធនឹង
សកម្មភាព
ដែលគ្រោង ធ្វើទាំងអស់។ ព័ត៌មានគឺមានភាពច្បាស់លាស់ មិនផ្លាស់ប្តូរ
និងមានតម្លាភាព ហើយប្រើភាសាដែលអ្នកយល់បាន។


កាំផង៖ តើគោលការណ៍នេះមានសារៈសំខាន់យ៉ាងម៉េចទៅ?
ដារី ៖ ចាស! សារៈសំខាន់របស់វាគឺថាសហគមន៍មិនត្រូវបានបង្ខំអោយផ្លាស់ប្តូរលំនៅដ្ឋាន ដីធ្លី ដោយគ្មានការព្រមព្រៀងជាមុនហើយពួកគាត់មានសិទ្ធិគ្រប់គ្រាន់ក្នុងការថែរក្សា ការពារ និងអភិវឌ្ឍន៍នូវបរិស្ថាន ធនធានធម្មជាតិ កសិកម្មនិងប្រពៃណីវប្បធម៌។ គោលការណ៍នេះតំរូវអោយអ្នកគ្រប់គ្រងនិងអនុវត្តគំរោងអភិវឌ្ឍន៍ គោរព និងប្រឹក្សាយោបល់ និងសហការណ៍ជាមួយសហគមន៍ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានដើម្បីទទួលបាននូវការជឿទុកចិត្តនិងយល់ព្រមជាមុនសំរាប់អនុវត្តន៍គំរោង អភិវឌ្ឍន៍ណាមួយ។
រចំ ៖ ស្តាប់ទៅគួរអោយចាប់អារម្មណ៍ណាស់! ចុះយើងអាចអនុវត្តន៍គោលការណ៍នេះយ៉ាងម៉េចទៅ?
ដារី ៖ យើងអាចអនុវត្តន៍គោលការណ៍ “ការព្រមព្រៀង៖ ដោយសេរី ជាមុន និងផ្តល់ព័ត៌មាន” ទៅតាមជំហ៊ានទាំង៧។
កាំផង ៖ ជំហ៊ានទាំង៧មានអ្វីខ្លះទៅអ្នកគ្រូ?


ដារី ៖ ជំហ៊ានទី១ ៖ ស្វែងរកថា អ្នកណាកំពុងមានផែនការសកម្មភាព ដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ណា មួយលើដែនដីយើងកំពុងរស់នៅ ហើយគំរោងមានផលប៉ះពាល់ដល់ការរស់នៅ និងសិទ្ធិរបស់ សហគមន៍។


ជំហ៊ាន ទី២ ៖ ស្នើព័ត៌មានពីអ្នកគ្រប់គ្រងគំរោងអភិវឌ្ឍន៍។ ការដឹងពីប្រភេទនៃគំរោងស្នើ ឡើងហើយវាមានឥទ្ធិពលទៅលើសហគមន៍របស់យើងសំខាន់ណាស់សំរាប់ធ្វើការ ពិចារណា និងសំរេចចិត្ត ថាតើត្រូវផ្តល់ រឺ បដិសេដ រឹការផ្លាស់ប្តូរអ្វីខ្លះដែលអ្នកចង់អោយគំរោងរៀបចំឡើង និងលក្ខខណ្ឌដែលអ្នកត្រូវការមុននឹងអ្នកឯកភាពលើគំរោង។ អ្នកអាចស្នើព័ត៌មានពីគំរោងជាភាសា និងនៅក្នុងទំរង់ណាមួយ ដែលសហគមន៍របស់អ្នកអាចយល់បាន។ ក្នុងនេះយើងអាចសួរថា តើគំរោងនឹងធ្វើអ្វី? ពេលណា? រយៈពេលប៉ុន្មាន? មានផលប្រយោជន៍អ្វីខ្លះសំរាប់សហគមន៍? មានការជានា រឺ ទូទាត់សំណងដល់សហគមន៍យ៉ាងម៉េច? តើប៉ះពាល់ដល់សិទ្ធិសហគមន៍សហគមន៍ ដីធ្លី និងធនធានធម្មជាតិយ៉ាងម៉េចខ្លះ?
ជំហ៊ានទី៣ ៖ ធ្វើការពិភាក្សានៅក្នុងសហគមន៍របស់អ្នក។ អ្នកគួរធ្វើការពិភាក្សាជាមួយអ្នកគ្រប់គ្រង គំរោងអភិវឌ្ឍន៍ពីគំរោងលំអិតនៅក្នុងសហគមន៍របស់អ្នក ដើម្បីអោយសហគមន៍បានយល់ពីផល ប្រយោជន៍ និងឥទ្ធិពលរបស់គំរោង ហើយធ្វើការចរចាររកដំណោះស្រាយ និងការឯកភាពជារួម។ អ្នកមិនត្រូវធ្វើការសំរេចចិត្តណាមួយនៅក្នុងដំណាក់កាលនេះទេ។


ជំហ៊ានទី៤៖
ចរចារជាមួយអ្នកគ្រប់គ្រងគំរោងអភិវឌ្ឍន៍។
អ្នកមានសិទ្ធិពិគ្រោះយោបល់ និងចរចារជាមួយអ្នក
គ្រប់គ្រងគំរោងអភិវឌ្ឍន៍ ដើម្បីទាមទារសិទ្ធិរបស់អ្នក
ក្នុងការទទួលបានព័ត៌មាននិងលក្ខខណ្ឌផ្សេងៗ
អំពីគំរោងហើយអ្នកគ្រប់គ្រងគំរោងក៏ត្រូវចរចារ
ដើម្បីទទួលបាននូវការយល់ព្រមជាមុន
លើគំរោង របស់ខ្លួនពីសហគមន៍ផងដែរ។
ជំហ៊ានទី៥៖
ពិគ្រោះយោបល់ជាមួយអ្នកឯកទេស និងអ្នកច្បាប់។
យើងមិនត្រូវឯកភាពទាំងស្រុងលើព័ត៌មាន គំរោងនោះទេ។
យើងត្រូវរកការពិគ្រោះយោបល់បន្ថែម
ជាមួយអ្នកឯកទេស និងអ្នកច្បាប់ ដើម្បីស្វែង
យល់ពីឥទ្ធិពលគំរោង។
ជំហ៊ានទី៦ ៖
ធ្វើការសំរេចចិត្ត។ សហគមន៍
ត្រូវធ្វើការសំរេចចិត្តតាមបែបប្រពៃណីរួមគ្នា
និងដោយលាយលក្ខអក្សរលើគំរោងណាដែល
ព្រមព្រៀងជាមួយអ្នកគ្រប់គ្រងគំរោង។ អ្នកអាច និយាយ
បដិសេដចំពោះគំរោងដែលអ្នកយល់ថាមិនល្អ ។


ចំណែកជំហ៊ានទី៧ គឺ ៖
ទំនាក់ទំនងជាមួយអ្នកគ្រប់គ្រងគំរោងអភិវឌ្ឍន៍។ គំរោងអភិវឌ្ឍន៍ខ្នាតធំ
ត្រូវចំណាយពេលជាច្រើនឆ្នាំក្នុងការអនុវត្ត ហើយមានឥទ្ធិពលលើសហគមន៍
របស់អ្នកជាច្រើនឆ្នាំ។ ដូច្នេះ អ្នកត្រូវសួរសំណួរ និងលើកឡើងនូវកង្វល់
ជាមួយអ្នកគ្រប់គ្រងគំរោងអភិវឌ្ឍន៍អោយផ្តល់ ព័ត៌មាន និងចំលើយតបជា
ទៀងទាត់ អំពីភាពរីកចំរើនរបស់គំរោង និងភាព
ទទួលខុសត្រូវរបស់ខ្លួន។


ពូកាណុង៖ ពិតជាប្រសើរណាស់លោកគ្រូអ្នកគ្រូ! ដូច្នេះក្នុងនាមយើងជាជនជាតិដើមភាគតិច យើងគប្បី ប្រើសិទ្ធិរបស់យើងសំរាប់ ការអភិវឌ្ឍន៍ដោយនិរន្តរភាពនៅ សហគមន៍របស់យើង។
មីងនាង៖ អរគុណ និងអ្នកគ្រូខ្លាំងណាស់ ដែល បានពន្យល់ប្រាប់ពួកខ្ញុំទាំងអស់គ្នាអោយ បានយល់ពីសារៈសំខាន់នៃ គោលការណ៍នេះ។
មេភូមិ៖ យើងគួរតែចែករំលែក ចំណេះដឹងនេះទៅដល់អ្នកភូមិយើង ផ្សេងទៀតដែលមិនបានចូលរួមផងណា ដើម្បីអោយបានយល់ដឹង ទាំងអស់គ្នា។

---------អ្នកភូមិទាំងអស់ស្រែកព្រមគ្នា ៖




វុធ និងដារី ៖ ឆ្លើយព្រមគ្នា !!!អរគុណណាស់ពូមេភូមិ
និយាយអញ្ចឹងអ្នកគ្រូលោកគ្រូអញ្ជើញទៅហូបបាយថ្ងៃត្រង់នៅផ្ទះខ្ញុំម្តងទៅ!!!!
ពួកខ្ញុំត្រូវប្រញាប់ទៅប្រជុំនៅភូមិផ្សេងទៀតនៅល្ងាចនេះ។
-------អ្នកទាំងអស់បែកគ្នាពីទីកន្លែងប្រជុំ ហើយចាកចេញទៅផ្ទះរៀងៗខ្លួន។

# ឯកសារយោង

•សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច

•មគ្គុទេសអំពីសេរីភាព ការទទួលបានព័ត៌មនជាមុន  និងការយល់ព្រម ( អុកស្វាម)

•ការអនុវត្តសិទ្ធិ ( ការព្រមព្រៀង ដោយសេរី និងជូនដំណឹងជាមុនសម្រាប់ជនជាតិដើមភាគតិច) ដែលផលិតដោយ កតិកាសញ្ញាជនជាតិដើមភាគតិចនៅអាស៊ី ( AIPP )

•ការការពារ ការគោរព និងដំណោះស្រាយ - គោលការណ៍ណែនាំស្តីពី ធុរកិច្ច និងសិទ្ធិមនុស្ស បោះពុម្ពផ្សាយដោយ ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ( ការិយាល័យOHCH )    សហការ ជាមួយអង្គការគាំទ្រសហគមន៍ជនជាតិដើមភាគតិច (អង្គការICSO) ខែកុម្ភៈ ឆ្នាំ២០១៣

. UN-REDD - Programme - Application of Free, Prior, Informed and Consent Experience from UN-REDD

DPA

DEVELOPMENT AND PARTNERSHIP IN ACTION

EUROPEAN COMMISSION

Trōcaire

Working for a just world.

OXFAM

NORWEGIAN PEOPLE'S AID

CANADIAN CATHOLIC ORGANIZATION FOR

Development and Peace